ទីក្រុង Yaounde ប្រទេសកាមេរូន ថ្ងៃទី ១៥-១៧ ខែវិច្ឆិកា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## វេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មាន ដើម្បីគោលបំណងពន្ធដារ (Global Forum on Transparency and Exchange of Information for Tax Purpose - Global Forum)




តាមការចាត់តាំងដ៏ខ្ពង់ខ្ពស់ របស់ថ្នាក់ដឹកនាំ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ និងឆ្លើយតបតាមការអញ្ជើញ របស់វេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធដារ (Global Forum on Transparency and Exchange of Information for Tax Purpose - Global Forum) គណៈប្រតិភូ នៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំដោយលោក **ជ័យ រិទ្ធី** អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ បានចូលរួមកិច្ចប្រជុំពេញអង្គ លើកទី១០ របស់ Global Forum) ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ១៥-១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧ នៅទីក្រុង Yaounde ប្រទេសកាមេរូន ក្រោមអធិបតីភាពឯកឧត្តម **Alamine Ousmane Mey** រដ្ឋមន្ត្រីហិរញ្ញវត្ថុនៃសាធារណរដ្ឋកាមេរូន និងលោកជំទាវ **Maria- Jose Garde** ប្រធាន Global Forum ព្រមទាំងមានការចូលរួម ពីគណៈប្រតិភូ ដែលជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, រដ្ឋលេខាធិការ ក្រសួងហិរញ្ញវត្ថុ, អគ្គនាយក, អគ្គស្នងការនៃរដ្ឋបាលសារពើពន្ធ ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ពីប្រទេស និងយុត្តាធិការ ជាសមាជិក និងតំណាងអង្គការអន្តរជាតិនានា សរុបចំនួន ១៨៦ នាក់។

Global Forum ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ ដោយ

ប្រទេសសមាជិក នៃអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច (OECD) ហើយបច្ចុប្បន្ននេះ Global Forum មានសមាជិកសរុបចំនួន ១៤៧ ដែលធ្វើឱ្យយន្តការនៃការផ្លាស់ប្តូរព័ត៌មានរបស់ Global Forum កាន់តែមានភាពទូលំទូលាយជាពិសេស តាមការអនុវត្តស្តង់ដារនៃការផ្លាស់ប្តូរព័ត៌មានតាមការស្នើសុំ (Exchange of information on request - EOIR) និងការផ្លាស់ប្តូរព័ត៌មានជាលក្ខណៈស្វ័យប្រវត្តិ (Automatic exchange of information - AEOI) សំដៅធានាបាន នូវតម្លាភាព និងប្រសិទ្ធភាពនៃការប្រមូលពន្ធ ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងការគេចវេះពន្ធនៅបរទេស។ នៅក្នុងកិច្ចប្រជុំនេះ Global Forum បានសំដែងកិច្ចស្វាគមន៍ ចំពោះសមាជិកថ្មីចំនួន ១០ រួមមានព្រះរាជាណាចក្រកម្ពុជាផងដែរ ដែលបានចូលជាសមាជិកនៃវេទិកាសកលនេះ កាលពីខែសីហា ឆ្នាំ២០១៧កន្លងមក។

កិច្ចប្រជុំពេញអង្គលើកទី១០នេះបានពិនិត្យលើសមិទ្ធផលដែល Global Forum សម្រេចបាន ក្នុងការបន្តកិច្ចសហប្រតិបត្តិការខ្ពស់ រវាងប្រទេសនិងយុត្តាធិការសមាជិក សំដៅធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃស្តង់ដារអន្តរជាតិ ក្នុងការផ្តល់លទ្ធភាពឱ្យរដ្ឋបាលពន្ធដារ មានយន្តការជាក់លាក់រឹងមាំក្នុងការប្រយុទ្ធប្រឆាំងការគេចវេះពន្ធនៅបរទេស។ ក្នុងន័យនេះ កិច្ចប្រជុំពេញអង្គបានពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តការផ្លាស់ប្តូរព័ត៌មាន ជាលក្ខណៈស្វ័យប្រវត្តិ ហើយប្រទេស និងយុត្តាធិការសមាជិក បានឯកភាពក្នុងការបន្តសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត សំដៅឱ្យកិច្ចសហប្រតិបត្តិការអន្តរជាតិផ្នែកពន្ធដារនេះ កាន់តែមានប្រសិទ្ធភាព និងឈានទៅដោះស្រាយបញ្ហាប្រឈមរួមគ្នា។ ទន្ទឹមនឹងនេះ កិច្ចប្រជុំពេញអង្គ ក៏បានសាទរចំពោះលទ្ធផលជាប្រវត្តិសាស្ត្រ



គឺការចាប់ផ្តើមនៃការផ្លាស់ប្តូរព័ត៌មានហិរញ្ញវត្ថុ (Exchange of financial account information) របស់ប្រទេសនិងយុត្តាធិការសមាជិកមួយចំនួន។ ជាមួយគ្នានេះ អង្គប្រជុំពេញអង្គបាន៖

១- អនុម័តផែនការសកម្មភាព សម្រាប់ការចូលរួមរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការអនុវត្តការផ្លាស់ប្តូរព័ត៌មានជាលក្ខណៈស្វ័យប្រវត្តិ ដើម្បីឱ្យប្រទេសទាំងនេះអាចត្រៀមខ្លួន បំពេញតាមស្តង់ដារនានាផង អាចទទួលបានហិរញ្ញប្បទានបច្ចេកទេស ពីដៃគូអភិវឌ្ឍន៍ និងប្រទេសសមាជិក ព្រមទាំងអាចកំណត់កាលវិភាគនិងអាចទទួលបានអត្ថប្រយោជន៍ពីការអនុវត្ត AEOI នាពេលខាងមុខផង។ ផែនការសកម្មភាពនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍បីឆ្នាំចុងក្រោយរបស់ Global Forum លើការអនុវត្តគម្រោងនាំមុខ នៃផ្លាស់ប្តូរព័ត៌មាន ដោយស្វ័យប្រវត្តិ និងសកម្មភាពហិរញ្ញប្បទាន បច្ចេកទេសរបស់ខ្លួន។

២- ឯកភាពផ្តល់កិច្ចគាំទ្រយ៉ាងជិតស្និត ក្នុងដំណាក់កាលដំបូង បន្ទាប់ពីការចូលជាសមាជិករបស់ប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈកម្មវិធីបណ្តុះបណ្តាលជាក់លាក់ (Induction Program) ចំពោះសមាជិកចំនួន ២០ អំពីការផ្លាស់ប្តូរព័ត៌មាន។

៣- ផ្សព្វផ្សាយនូវរបាយការណ៍ចំនួន ១៦ ស្តីពីលទ្ធផលនៃការវាយតម្លៃអញ្ញមញ្ញជុំទីពីរ (Second round of peer reviews) នៃប្រទេសឬយុត្តាធិការសមាជិកចំនួន ៣៦ និងបានជំរុញឱ្យប្រទេសសមាជិកបន្តកិច្ចខិតខំ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាពីព្រោះតាមលទ្ធផលខាងលើថ្វីបើប្រទេសមួយចំនួនបានលទ្ធផលល្អ ក៏ប៉ុន្តែប្រទេសមួយចំនួនពុំទាន់បានចំណាត់ថ្នាក់ល្អនោះទេ។ Global Forum គ្រោងនឹងអនុវត្តការវាយតម្លៃអញ្ញមញ្ញ ជាង ១៣០ ទៀតសម្រាប់ឆ្នាំ ២០១៨-២០២១។ គួរបញ្ជាក់ថា ការវាយតម្លៃអញ្ញមញ្ញជុំទី១ កន្លងមក ដែលមានចំនួន ១១៩ បានបញ្ចប់ និងបានផ្តល់ចំណាត់ថ្នាក់រួចហើយ។ សម្រាប់ជុំទីពីរនេះ ការវាយតម្លៃបានផ្តោតជាសំខាន់លើតម្លាភាពពន្ធដារអន្តរជាតិ រួមបញ្ចូលទាំងលក្ខខណ្ឌនៃការស្វែងរក

ម្ចាស់កម្មសិទ្ធិដែលទទួលផលប្រយោជន៍ (Beneficial ownership) ពិតប្រាកដ។

៤- គូសបញ្ជាក់ឡើងវិញអំពីតួនាទីរបស់ Global Forum ដែលជាស្ថាប័នអន្តរជាតិ នាំមុខលើបញ្ហាតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធដារ និងបានប្តេជ្ញាចិត្ត បន្តជំរុញគ្រប់ភាគីទាំងអស់ ដែលពាក់ព័ន្ធនឹងបញ្ហាតម្លាភាពពន្ធដារ ឱ្យស្ថិតនៅក្នុងគន្លង ស្របនឹងការងាររបស់ Global Forum ដើម្បីធានានូវភាពត្រឹមត្រូវ និងសង្គតិភាពនឹងការងារនេះ។

៥- ពិនិត្យនិងពិភាក្សាលើលក្ខខណ្ឌរបស់សហភាពអឺរ៉ុប (EU listing process) ពាក់ព័ន្ធនឹងតម្លាភាពពន្ធដារ និងបានស្នើឱ្យក្រុមក្រមសីលធម៌របស់សភាពអឺរ៉ុប (EU Code of Conduct Group) ធ្វើការរួមគ្នាដើម្បីពិភាក្សាលើបែបបទ និងកាលវិភាគនៃបញ្ហានេះ។

៦- បន្តជំរុញឱ្យសមាជិកចំនួន ៥៣ ដែលបានផ្តល់ការសន្យារួចហើយ ឱ្យអនុវត្តឱ្យបានពេញលេញ នូវការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិ នៅឆ្នាំ២០១៨ ខាងមុខតាមការសន្យា។

៧- ឯកភាពលើផែនការទំនាក់ទំនងបណ្តោះអាសន្នស្តីពីការរក្សាការសម្ងាត់នៃព័ត៌មាន ដែលត្រូវបានផ្លាស់ប្តូរ ដើម្បីធានាបាននូវប្រសិទ្ធភាព នៃការរក្សាការសម្ងាត់ និងសុវត្ថិភាពទិន្នន័យ។

៨- បន្តឃ្លាំមើលក្របខ័ណ្ឌអន្តរជាតិ នៃការផ្លាស់ប្តូរព័ត៌មាន និងបន្តពង្រីកបណ្តាញនៃការផ្លាស់ប្តូរព័ត៌មាន។

៩- ផ្តល់ភារកិច្ចឱ្យក្រុមការងារ នៃការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិ(AEOIGroup)រៀបចំនូវការពិពណ៌នាការងារ (ToR)និងវិធីសាស្រ្តសម្រាប់ការវាយតម្លៃអញ្ញមញ្ញពេញលេញ សម្រាប់អនុវត្តនៅឆ្នាំ២០២០ ដើម្បីការពិនិត្យ និងអនុម័តរបស់កិច្ចប្រជុំពេញអង្គនៃ Global Forum នៅឆ្នាំ២០១៨។ យ៉ាងណាមិញ ក្នុងខណៈនេះ ត្រូវបន្តអនុវត្តតារាងវាយតម្លៃតាមដំណាក់កាល (Staged approach) ដើម្បីពិនិត្យ វាយតម្លៃ និងផ្តល់កិច្ចគាំទ្រដល់ការអនុវត្តស្តង់ដារនៃផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិ។

១០- ស្វាគមន៍ចំពោះលទ្ធផលជោគជ័យ នៃដាក់ចេញនូវនីតិវិធី វាយតម្លៃអញ្ញមញ្ញបំព្រួញ (Fast-Track review procedure) តាមការអំពាវនាវរបស់ប្រទេស G20 ដើម្បីអនុញ្ញាតឱ្យប្រទេសសមាជិក អាចតម្លើងកម្រិត ចំពោះលទ្ធផល នៃការវាយតម្លៃអញ្ញមញ្ញ។

១១- ស្វាគមន៍ ចំពោះការដាក់ឱ្យអនុវត្តផែនការបីឆ្នាំបន្ទាប់ស្តីពីគំនិតផ្តួចផ្តើមអាហ្វ្រិក (Africa Initiative) ដើម្បីបន្តគាំទ្រ និងផ្តល់ហិរញ្ញប្បទានដល់ប្រទេសនៅទ្វីបអាហ្វ្រិក លើការផ្លាស់ប្តូរព័ត៌មាន។

១២- សម្រេចបន្តអាណត្តិការងារជូនប្រធាន និងអនុប្រធាននៃក្រុមការងារផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិ (AEOI Group) ចំនួន ២ ឆ្នាំទៀត រហូតដល់ឆ្នាំ ២០១៩។

១៣- ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន សម្រាប់ឆ្នាំ២០១៧ និងបានអនុម័តលើគម្រោងថវិកាឆ្នាំ២០១៨

១៤- បន្តធ្វើការវាយតម្លៃ អំពីផលប៉ះពាល់នៃការងាររបស់ Global Forum មួយទសវត្សរ៍កន្លងមកនេះ ជាពិសេសចំពោះការងារលើការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិ។

១៥- ឯកភាពលើសកម្មភាពជាគន្លឹះសម្រាប់ឆ្នាំ ២០១៨ រួមមាន៖ ការបំពេញការសន្យារបស់ប្រទេសសមាជិក ដែលគ្រោងធ្វើការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិ នៅឆ្នាំ២០១៨, ការរៀបចំក្របខ័ណ្ឌនៃការវាយតម្លៃអញ្ញមញ្ញពេញលេញ, វឌ្ឍនភាព នៃការអនុវត្តស្តង់ដារផ្លាស់ប្តូរព័ត៌មាន ដោយស្វ័យប្រវត្តិរបស់ប្រទេសកំពុងអភិវឌ្ឍន៍,ការបន្តផ្សព្វផ្សាយរបាយការណ៍នៃការវាយតម្លៃអញ្ញមញ្ញជុំទីពីរ, ការវាយតម្លៃ និងការផ្តល់ហិរញ្ញប្បទានបច្ចេកទេសលើព័ត៌មានស្តីពីម្ចាស់កម្មសិទ្ធិ លើអត្ថប្រយោជន៍ (Beneficial ownership information)។

កិច្ចប្រជុំពេញអង្គលើកទី១០ របស់ Global Forum បានបញ្ចប់នៅរសៀលថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្នុងបរិយាកាសសោមនស្សរីករាយ ហើយអង្គប្រជុំបានឯកភាពលើកាលបរិច្ឆេទនិងទីកន្លែងនៃកិច្ចប្រជុំពេញអង្គបន្ទាប់របស់ Global Forum ដែលនឹងប្រព្រឹត្តទៅនៅខែតុលា ឬវិច្ឆិកា ឆ្នាំ២០១៨ នៅប្រទេសអ៊ុយរ៉ាហ្គាយ៕